# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបតំណាង **ADB** ប្រចាំកម្ពុជា ដែលទើបតែងតាំងថ្មី



នៅរសៀលថ្ងៃទី១១ ខែ មីនា ឆ្នាំ២០១៦ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបលោក **Samiuela Tukuafu** តំណាងប្រចាំប្រទេសនៃធនាគារអភិវឌ្ឍន៍អាស៊ី ADB ដែលទើបតែងតាំងថ្មីនៅកម្ពុជា ដើម្បីពិភាក្សាការងារនៅទីស្តីការក្រសួង ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះសកម្មភាពការងាររបស់ធនាគារ ADB នៅកម្ពុជា ក្នុងការរួមចំណែកជម្រុញអភិវឌ្ឍន៍សេដ្ឋកិច្ច និងអភិបាលកិច្ចល្អនៅកម្ពុជា ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានថ្លែងអំណរគុណចំពោះធនាគារ ADB ដែលបានអនុវត្តគម្រោងការសំខាន់ៗជាច្រើនជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាពិសេសវិស័យទឹកស្អាត អភិវឌ្ឍន៍វិស័យសហគ្រាសធុនតូច និងមធ្យម ការបណ្តុះបណ្តាលធនធានមនុស្ស និងជំនួយបច្ចេកទេសនានា ។



ឆ្លៀតឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានសង្កត់ធ្ងន់ឱ្យធនាគារ ADB ចាប់អារម្មណ៍ជាសំខាន់ទៅលើការងារអភិវឌ្ឍន៍វិស័យទឹកស្អាត នៅតំបន់ទីក្រុង ទីប្រជុំជន តំបន់មាត់សមុទ្រ តំបន់ទេសចរណ៍ តំបន់សេដ្ឋកិច្ចពិសេស ជាដើម ពីព្រោះឯកឧត្តមគិតថា មានទឹកស្អាត នឹងមានការអភិវឌ្ឍន៍ តាមរយៈការទាក់ទាញទុនវិនិយោគ របាយប្រជាជនកើនឡើង ដែលនឹងធ្វើឱ្យមានការរីកលូតលាស់ក្នុងតំបន់គោលដៅនោះយ៉ាងឆាប់រហ័ស។ ប៉ុន្តែឯកឧត្តម ទេសរដ្ឋមន្ត្រី បានទាញអារម្មណ៍ថា ការផលិតទឹកស្អាតគឺមិនមែនផលិតសម្រាប់តែបង្គ្រប់ការប្រើប្រាស់ប៉ុណ្ណោះទេ តែត្រូវគិតជាសំខាន់ទៅលើគោលការណ៍ ០៤យ៉ាងយ៉ាងតិច គឺៈគុណភាព–សុវត្ថិភាព–និរន្តរភាព និងតម្លៃសមរម្យ ។ ឯកឧត្តម បានបញ្ជាក់ថាៈ នៅតំបន់មួយចំនួន ទោះបីការផលិតចែកចាយទឹកស្អាត ក្រោមការគ្រប់គ្រងវិនិយោគ របស់ឯកជន ក៏រដ្ឋនៅតែមានយន្តការតាមដាន និងជួយបទដ្ឋានបច្ចេកទេសដល់ពួកគាត់ផងដែរ ។ កត្តានេះ ឯកឧត្តម បានចាត់ទុកការផ្តល់ជំនួយបច្ចេកទេស ការបណ្តុះបណ្តាលធុនធានមនុស្ស ជាបញ្ហាសំខាន់ ដែលឯកឧត្តមស្នើស្នើឱ្យ ADB ពិនិត្យលទ្ធភាពជាក់ស្តែង ដើម្បីពង្រឹងសមត្ថភាពវិស័យផលិតទឹកស្អាតទាំងផ្នែករដ្ឋនិងឯកជន ។ ក្នុងនោះ ការធ្វើតេស្តគុណភាពទឹកជាប្រចាំ ដើម្បីឱ្យប្រាកដថា ទឹកមានសុវត្ថិភាព គ្មានការប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ គឺត្រូវមានការគិតគូ តាមរយៈការផ្តល់អាទិភាពទៅលើមន្ទីរពិសោធន៍ចល័តតាមរថយន្ត។

លោក **Samiuela Tukuafu** តំណាងប្រចាំប្រទេសនៃធនាគារអភិវឌ្ឍន៍អាស៊ី ADB ដែលទើបតែងតាំងថ្មី នៅកម្ពុជា បានវាយតម្លៃខ្ពស់ចំពោះស្ថានភាពរីកចម្រើនផ្នែកសេដ្ឋកិច្ចនៅកម្ពុជា ។ ក្នុងនោះលោកក៏បានលើកឡើងពីសកម្មភាពការងារជាច្រើន ដែលធនាគារ ADB អនុវត្តនៅកម្ពុជា ដូចជាៈវិស័យហេដ្ឋារចនាសម្ព័ន្ធ –កសិកម្ម–អភិវឌ្ឍន៍ជនបទ និងវិស័យមីក្រូហិរញ្ញវត្ថុជាដើម ។ ដោយឡែកជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ធនាគារ ADB បានយកចិត្តជាសំខាន់ ទៅលើ

វិស័យទឹកស្អាត-អភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម ។ លោកបានបញ្ជាក់ថា: ក្នុងបេសកកម្មរបស់លោក នឹងខិតខំសម្រេចឱ្យបាននូវគម្រោងនានា ដែល ADB មានជាមួយកម្ពុជា ។ ក្នុងនោះគម្រោងពង្រីកវិស័យទឹកស្អាត នៅខេត្តកំពត និងខេត្តស្វាយរៀង នឹងចេញជាឯកសារគោល នៅខែ ឧសភា ខាងមុខនេះហើយ ។